ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន | ពិធីសម្ពោធដំណើរការគម្រោងអភិបាលកិច្ច

**រាជធានីភ្នំពេញ – ប្រទេសកម្ពុជា៖** អង្គការវីអេសអូកម្ពុជា និងដៃគូអនុវត្តគម្រោងរួមមាន គណៈកម្មការសហប្រតិបត្តិការដើម្បីកម្ពុជា វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា អង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា នឹងធ្វើការសម្ពោធដំណើរការគម្រោង "ការពង្រឹងបណ្តាញអង្គការសង្គមស៊ីវិលដើម្បីការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន" នៅថ្ងៃអង្គារ៍ ទី៣០ ខែសីហា ឆ្នាំ២០១៦ ពេលរសៀល ចាប់ពីម៉ោង២ រហូតដល់ម៉ោង៥រសៀល នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។ ពិធីនេះនឹងបង្ហាញជាផ្លូវការនៃការចាប់ផ្តើមគម្រោង។

គម្រោងមានរយៈពេល៣០ខែនេះ នឹងអនុវត្តក្រោមការគាំទ្រពីតំណាងសហភាពអឺរ៉ុបប្រចាំកម្ពុជា។ គម្រោងនេះនឹងផ្តល់ការពង្រឹងបណ្តាញអង្គការសង្គមស៊ីវិល ដើម្បីក្លាយខ្លួនទៅជាតួអង្គសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ច និងគណនេយ្យភាព និងជម្រុញឱ្យមានការបង្កើតគោលនយោបាយប្រកបដោយបរិយាប័ន្ន។ គម្រោងនេះនឹងបង្កើនសមត្ថភាពលើការគ្រប់គ្រងស្ថាប័នបណ្តាញ ការគ្រប់គ្រងចំណេះដឹង ការកៀរគរធនធាន និងការតស៊ូមតិ ដើម្បីបង្កើតឱ្យមាននូវលទ្ធផលកាន់តែទៅដល់ប្រជាពលរដ្ឋក្នុងខេត្តទាំង៨ រួមមាន៖ សៀមរាប កំពង់ធំ ព្រៃវែង ស្វាយរៀង ក្រចេះ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី។

លោក Guillaume Sauval នាយកប្រចាំប្រទេសនៃអង្គការវីអេសអូកម្ពុជាមានប្រសាសន៍ថា "មានតម្រូវការយ៉ាងខ្លាំងដើម្បីការពារ និងបើកចំហរឱកាសដល់សង្គមស៊ីវិលក្នុងការគាំទ្រដល់សកម្មភាពដែលនាំមុខដោយប្រជាពលរដ្ឋ ក្នុងការពង្រឹងគណនេយ្យភាព។ អង្គការវីអេសអូ បានបញ្ជ្រាបវត្តមានរបស់ខ្លួន ជាប្រចាំថ្ងៃ និងរយៈពេលវែង ដើម្បីធ្វើការជាមួយអង្គការសង្គមស៊ីវិលនៅថ្នាក់មូលដ្ឋាន និងស្ថាប័នរាជរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ។ ដៃគូរបស់យើងជាច្រើនបានប្រាប់យើងថា ពួកគេចាត់ទុកអង្គការវីអេសអូជាអ្នកសម្របសម្រួលប្រកបដោយភាពជឿជាក់ និងជាអ្នកផ្សាយភ្ជាប់រវាងរដ្ឋាភិបាល និងសង្គមស៊ីវិល។ ដោយមានការគាំទ្រពីតំណាងសហភាពអឺរ៉ុបប្រចាំកម្ពុជា គម្រោងរួមគ្នានេះគឺជាសញ្ញានៃការប្តេជ្ញាចិត្តដ៏ខ្លាំងក្លាមួយពីគ្រប់ដៃគូទាំងអស់ ដែលបានចូលរួមក្នុងការគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាឆ្ពោះទៅរកវិធីសាស្រ្តប្រកបដោយបរិយាប័ន្នចំពោះការអភិវឌ្ឍ។"

ឯកឧត្តម **ង៉ាន់ ចំរើន** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានប្រតិបត្តិនៃគណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នឹងអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដំណើរ

ការគម្រោងនេះ។ កម្មវិធីនេះនឹងមានអ្នកចូលរួមប្រមាណ១០០នាក់ រួមមានដៃគូអភិវឌ្ឍន៍ តំណាងស្ថានទូត អង្គការជាតិនិងអន្តរជាតិ តំណាងបណ្ដាញអង្គការសង្គមស៊ីវិលនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សារព័ត៌មាន ដៃគូអនុវត្តគម្រោង និងស្ថាប័នផ្សេងទៀតដែលធ្វើការទៅលើវិស័យជាក់លាក់រួមមានយុវជន កុមារ យេនឌ័រ និងជនពិការ។

អង្គការវីអេសអូកម្ពុជា ដើរតួនាទីជាអ្នកសម្របសម្រួលក្នុងការគ្រប់គ្រង និងការធានានូវការអនុវត្តគម្រោងប្រកដោយគុណភាពខ្ពស់។ ក្នុងតួនាទីជាដៃគូអនុវត្តគម្រោង គណៈកម្មការសហប្រតិបត្តិការដើម្បីកម្ពុជានឹងកសាងសមត្ថភាពរបស់បណ្ដាញអង្គការសង្គមស៊ីវិល លើ ការគ្រប់គ្រងស្ថាប័ន ការគ្រប់គ្រងចំណេះដឹង និងសមត្ថភាពក្នុងការកៀរគរធនធាន។ វេទិការនៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា នឹងសម្របសម្រួលសកម្មភាពនៃការតស៊ូមតិ ហើយអង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជានឹងធានាអំពីការបញ្ជ្រាបយេនឌ័រនៅគ្រប់សកម្មភាពទាំងអស់របស់គម្រោង។

នៅពេលបញ្ចប់កម្មវិធី នឹងមានការផ្ដល់ភេសជ្ជៈ និងអាហារសម្រន់សម្រាប់ការបង្កើនភាពស្និទ្ធស្នាល និងបង្កើនបណ្ដាញចាប់ពីម៉ោង ៤.១០នាទីរសៀល តទៅនៅបន្ទប់ **ទន្លេចតុមុខ** នៃសណ្ឋាគារ **កាំបូឌីយ៉ាណា**។ អ្នកសារព័ត៌មាននឹងត្រូវបានស្វាគមន៍ដើម្បីសាកសួរព័ត៌មានបន្ថែមអំពីពីគម្រោង។

*មានការបកប្រែសម្រួលភាសាពីខ្មែរទៅអង់គ្លេស និងពីអង់គ្លេសទៅខ្មែរដោយមានឧបករណ៍ស្ដាប់សំលេង។*
*ព័ត៌មានបន្ថែមសូមទាក់ទង៖*

- *លោក រ័ត្ន តារាពិសួគ៌ ប្រធានគម្រោងអភិបាលកិច្ច តាមរយៈអ៊ីម៉ែល rath.darapisuor@vsoint.org ឬទូរសព្ទលេខ ០១០ ៦៧៦ ៣៣៥*

*--ចប់--*